**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**
**លេខ** ០៧៧ **គ.ជ.ប.** ស.ណ.ន

# សេចក្តីណែនាំ
# ស្តីពី
# ការចុះឈ្មោះបោះឆ្នោត
# សម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៥ ឆ្នាំ២០២៤

## គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ
- បានឃើញច្បាប់ស្តីពីវិសោធនកម្មច្បាប់បោះឆ្នោត
- បានឃើញសេចក្តីសម្រេចលេខ ៥៩ សសរ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២៣ របស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីការប្រកាសកាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា សម្រាប់នីតិកាលទី៥ នៃព្រឹទ្ធសភា
- បានឃើញបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា
- យោងប្រតិទិនសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៥ ឆ្នាំ២០២៤

ដើម្បីឱ្យដំណើរការនៃការចុះឈ្មោះបោះឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៥ ឆ្នាំ២០២៤ ប្រព្រឹត្តទៅដោយរលូន និងទាន់ពេលវេលា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) សូមធ្វើការណែនាំដល់អគ្គលេខាធិការដ្ឋានរដ្ឋសភា លេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត (លធ.ខប) អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត អភិបាលនៃគណៈ-អភិបាលក្រុង ស្រុក ខណ្ឌ និងក្រុមប្រឹក្សាឃុំ សង្កាត់ (កបឃ.ស) ត្រូវចាត់ចែង និងអនុវត្តការងារតាមខ្លឹមសារដូចខាងក្រោម ៖

## I- អគ្គលេខាធិការដ្ឋានរដ្ឋសភា

- ត្រូវរៀបចំការិយាល័យចុះឈ្មោះបោះឆ្នោតដែលអាចតាំងនៅបន្ទប់ដាច់ដោយឡែក ឬនៅបន្ទប់ធ្វើការរបស់អគ្គលេខាធិការរដ្ឋសភា ដើម្បីស្រង់ឈ្មោះអ្នកបោះឆ្នោត និងអង្គបោះឆ្នោតដែលជាតំណាងរាស្ត្រក្នុងតំណែងតាមគំរូបញ្ជីឈ្មោះដែលផ្តល់ជូនដោយ គ.ជ.ប

- ត្រូវបិទផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត និងបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត នៅមុខទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោតនៃអគ្គលេខាធិការដ្ឋានរដ្ឋសភា យ៉ាងតិច ៧ (ប្រាំពីរ) ថ្ងៃ មុនថ្ងៃចាប់ផ្តើមការចុះឈ្មោះបោះឆ្នោត
- បិទផ្សាយប្រតិទិននៃការចុះឈ្មោះបោះឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៥ ឆ្នាំ២០២៤ នៅមុខទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោតនៃអគ្គ-លេខាធិការដ្ឋានរដ្ឋសភា យ៉ាងតិច ៧ (ប្រាំពីរ) ថ្ងៃ មុនថ្ងៃចុះឈ្មោះបោះឆ្នោត
- បើកការិយាល័យចុះឈ្មោះបោះឆ្នោត ដើម្បីចុះឈ្មោះបោះឆ្នោត ចាប់ពីថ្ងៃទី១៨ ខែតុលា ដល់ថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០២៣ (មិនគិតបញ្ចូលថ្ងៃសៅរ៍ ថ្ងៃអាទិត្យ និងថ្ងៃបុណ្យផ្លូវការ) ។ អគ្គលេខាធិការរដ្ឋសភាត្រូវមានវត្តមាននៅការិយាល័យចុះឈ្មោះបោះឆ្នោត ក្នុងអំឡុងពេលនៃការចុះឈ្មោះបោះឆ្នោត ដើម្បីស្រង់ឈ្មោះ និងចុះឈ្មោះជូនតំណាងរាស្ត្រក្នុងតំណែង និងបំពេញទម្រង់បញ្ជីឈ្មោះតំណាងរាស្ត្រក្នុងតំណែង និងផ្តល់ព័ត៌មានឱ្យបានគ្រប់គ្រាន់ដល់តំណាងរាស្ត្រក្នុងតំណែងទាំងនោះ ។ អគ្គលេខាធិការរដ្ឋសភា ត្រូវ ៖
    - ➢ ស្រង់ឈ្មោះ និងទិន្នន័យតំណាងរាស្ត្រក្នុងតំណែង និងផ្ទៀងផ្ទាត់លក្ខខណ្ឌសម្រាប់ការចុះឈ្មោះបោះឆ្នោត ។ ក្នុងករណីពិនិត្យឃើញថាត្រឹមត្រូវពិតប្រាកដហើយ ត្រូវចុះឈ្មោះគាត់ចូលទៅក្នុងបញ្ជីឈ្មោះតំណាងរាស្ត្រក្នុងតំណែងជារូម តាមគំរូដែលផ្តល់ជូនដោយ គ.ជ.ប
    - ➢ ធានាថាឈ្មោះ និងទិន្នន័យតំណាងរាស្ត្រក្នុងតំណែងដែលបានចុះក្នុងបញ្ជីឈ្មោះដូចគ្នាជាមួយនឹងឈ្មោះ និងទិន្នន័យរបស់តំណាងរាស្ត្រក្នុងតំណែងនៅលើ អ.ខ ឬលិខិតសម្គាល់ខ្លួនជាតំណាងរាស្ត្រក្នុងតំណែងដែលចេញដោយប្រធានរដ្ឋសភា
    - ➢ ធានាថាតំណាងរាស្ត្រក្នុងតំណែងទាំងអស់នៅក្នុងក្របខណ្ឌរាជធានី ខេត្តនៃភូមិភាគនីមួយៗ ត្រូវបានស្រង់បញ្ចូលទៅក្នុងបញ្ជីឈ្មោះតំណាងរាស្ត្រក្នុងតំណែង
- បន្ទាប់ពីចុះឈ្មោះ និងទិន្នន័យតំណាងរាស្ត្រក្នុងតំណែង និងពិនិត្យ ផ្ទៀងផ្ទាត់ឈ្មោះ និងទិន្នន័យបានត្រឹមត្រូវ និងគ្រប់ចំនួនតាមអង្គបោះឆ្នោតហើយ ត្រូវថតចម្លងបញ្ជីនេះបន្ថែម ២ (ពីរ) ច្បាប់ទៀតរួចអគ្គលេខាធិការរដ្ឋសភា ត្រូវចុះហត្ថលេខា បោះត្រាអគ្គលេខាធិការដ្ឋានរដ្ឋសភា និងកាលបរិច្ឆេទ លើបញ្ជីឈ្មោះតំណាងរាស្ត្រក្នុងតំណែងទាំង ៣ (បី) ច្បាប់ រួចរៀបចំបញ្ជីឈ្មោះទាំងនោះជូនប្រធានរដ្ឋសភា ដើម្បីស្នើសុំបញ្ជាក់ការឯកភាព និងត្រូវប្រើប្រាស់ដូចខាងក្រោម ៖
    - ➢ ផ្ញើជូន គ.ជ.ប នូវច្បាប់ដើម ១ (មួយ) ច្បាប់ និងច្បាប់ចម្លង ១ (មួយ) ច្បាប់
    - ➢ រក្សាទុកជាឯកសារនៅអគ្គលេខាធិការដ្ឋានរដ្ឋសភា ១ (មួយ) ច្បាប់

- ធ្វើរបាយការណ៍សរុបលទ្ធផលនៃការចុះឈ្មោះបោះឆ្នោតនៅការិយាល័យចុះឈ្មោះបោះឆ្នោតនៃអង្គបោះឆ្នោតតំណាងរាស្ត្រក្នុងតំណែងចំនួន ២ (ពីរ) ច្បាប់ ហើយចាត់ចែងប្រើប្រាស់ដូចខាងក្រោម ៖
  - ➢ ផ្ញើជូន គ.ជ.ប (នាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត) ១ (មួយ) ច្បាប់
  - ➢ រក្សាទុកជាឯកសារនៅអគ្គលេខាធិការដ្ឋានរដ្ឋសភា ១ (មួយ) ច្បាប់
- ក្រោយពីបញ្ជូនបញ្ជីឈ្មោះតំណាងរាស្ត្រក្នុងតំណែងមក គ.ជ.ប ហើយក្នុងករណីមានអ្នកបោះឆ្នោតណាម្នាក់ ឬច្រើននាក់ ដែលបានចុះឈ្មោះក្នុងបញ្ជីបោះឆ្នោតដែលជាតំណាងរាស្ត្រក្នុងតំណែងរួចហើយ ប៉ុន្តែបែរជាលែងស្ថិតក្នុងតំណែងជាតំណាងរាស្ត្រតទៅទៀត និងដែលមានតំណាងរាស្ត្រក្នុងតំណែងថ្មីចូលមកជំនួសជាផ្លូវការ អគ្គលេខាធិការដ្ឋានរដ្ឋសភាត្រូវលើកសំណើសុំកែតម្រូវបញ្ជីបោះឆ្នោត ដោយមានការបញ្ជាក់ឯកភាពពីប្រធានរដ្ឋសភា មក គ.ជ.ប យ៉ាងយូរត្រឹមថ្ងៃទី៣ ខែមករា ឆ្នាំ២០២៤ ។

**II- លេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត**

- ធ្វើទំនាក់ទំនងជាមួយអាជ្ញាធរដែនដី គណបក្សនយោបាយ សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីផ្សព្វផ្សាយអំពីគោលបំណង ខ្លឹមសារនៃសេចក្តីណែនាំនេះ រួមទាំងប្រតិទិននៃការចុះឈ្មោះបោះឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាល-ទី៥ ឆ្នាំ២០២៤
- ផ្សព្វផ្សាយអំពីគោលបំណង ខ្លឹមសារ និងប្រតិទិននៃការចុះឈ្មោះសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែងដល់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ និងប្រធាន កបឃ.ស ពាក់ព័ន្ធទាំងអស់
- បញ្ជូនទម្រង់បញ្ជីឈ្មោះសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែង និងទម្រង់របាយការណ៍ស្តីពីលទ្ធផលនៃការស្រង់ឈ្មោះដែលផ្តល់ជូនដោយ គ.ជ.ប ទៅឃុំ សង្កាត់ពាក់ព័ន្ធទាំងអស់
- ធ្វើទំនាក់ទំនងជាប្រចាំ សម្របសម្រួល និងសហការឱ្យបានជិតស្និតជាមួយរដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្នុងការចុះទៅទទួលយកដោយផ្ទាល់នៅសាលាក្រុង ស្រុក ខណ្ឌ ឬ ក្នុងការចាត់ចែងបញ្ជូនបញ្ជីឈ្មោះ និងរបាយការណ៍សរុបលទ្ធផលនៃការចុះឈ្មោះបោះឆ្នោតពីគ្រប់ឃុំ សង្កាត់ទាំងអស់ដែលស្ថិតក្នុងរាជធានី ខេត្តជូនអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបញ្ជាក់ការឯកភាពលើបញ្ជីឈ្មោះសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែងនៃឃុំ សង្កាត់ទាំងអស់ដែលស្ថិតក្នុងរាជធានី ខេត្តពាក់ព័ន្ធសម្រាប់បញ្ជូនទៅ គ.ជ.ប ឱ្យបានឆាប់រហ័ស តាមដែលអាចធ្វើបាន

- ក្រោយពីទទួលបានបញ្ជីឈ្មោះសមាជិក កបយ.ស ទាំងអស់ក្នុងតំណែងដែលមានបញ្ជាក់ការឯកភាពពីអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត និងរបាយការណ៍សរុបលទ្ធផលនៃការចុះឈ្មោះបោះឆ្នោតតាមឃុំ សង្កាត់រួចមក លធ.ខប ត្រូវរៀបចំវេចខ្ចប់ បែងចែក និងប្រើប្រាស់បញ្ជីឈ្មោះ និងរបាយការណ៍ទាំងនោះដូចខាងក្រោម ៖
  - បញ្ជូនបញ្ជីឈ្មោះសមាជិក កបយ.ស ទាំងអស់ក្នុងតំណែងនៃឃុំ សង្កាត់នីមួយៗ ១ (មួយ) ច្បាប់ និងរបាយការណ៍សរុបលទ្ធផលនៃការចុះឈ្មោះបោះឆ្នោតតាមឃុំ សង្កាត់ ១ (មួយ) ច្បាប់ ជូន គ.ជ.ប
  - រក្សាទុកបញ្ជីឈ្មោះសមាជិក កបយ.ស ទាំងអស់ក្នុងតំណែងនៃឃុំ សង្កាត់នីមួយៗ ១ (មួយ) ច្បាប់ និងរបាយការណ៍សរុបលទ្ធផលនៃការចុះឈ្មោះតាមឃុំ សង្កាត់ ១ (មួយ) ច្បាប់ ជាឯកសារនៅ លធ.ខប
- ធ្វើរបាយការណ៍សរុបលទ្ធផលនៃការចុះឈ្មោះបោះឆ្នោតនៅគ្រប់ឃុំ សង្កាត់ទូទាំងរាជធានី ខេត្តចំនួន ២ (ពីរ) ច្បាប់ ដែលក្នុងនោះត្រូវ ៖
  - រក្សាទុក ១ (មួយ) ច្បាប់ ជាឯកសារនៅ លធ.ខប
  - បញ្ជូន ១ (មួយ) ច្បាប់ ជូន គ.ជ.ប (នាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត)
- ក្នុងករណីពិនិត្យឃើញថា ឈ្មោះសមាជិក កបយ.ស ក្នុងតំណែងណាមួយពុំមានឯកសារបញ្ជាក់គ្រប់គ្រាន់អំពីស្ថានភាពស្ថិតនៅក្នុងមុខតំណែង លធ.ខប ត្រូវរៀបចំតារាងបូកសរុបដោយឡែកមួយ និងធ្វើរបាយការណ៍អំពីករណីនេះមក គ.ជ.ប អំពីចំនួនសមាជិក កបយ.ស ដែលមិនត្រូវបានបញ្ចូលឈ្មោះក្នុងបញ្ជីបោះឆ្នោតដោយបញ្ជាក់មូលហេតុឱ្យបានច្បាស់លាស់ និងបញ្ជូនបញ្ជីនោះមក គ.ជ.ប ១ (មួយ)ច្បាប់ និងរក្សាទុកជាឯកសារនៅ លធ.ខប ១ (មួយ) ច្បាប់ ។

III- **ក្រុមប្រឹក្សាឃុំ សង្កាត់**
- រៀបចំការិយាល័យចុះឈ្មោះបោះឆ្នោត ដែលអាចតាំងនៅបន្ទប់ដាច់ដោយឡែក ឬនៅបន្ទប់ប្រធាន កបយ.ស ដើម្បីស្រង់ឈ្មោះអ្នកបោះឆ្នោត និងអង្គបោះឆ្នោតដែលជាសមាជិក កបយ.ស ទាំងអស់ក្នុងតំណែង តាមគំរូបញ្ជីឈ្មោះដែលផ្តល់ជូនដោយ គ.ជ.ប
- បិទផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត និងបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោតនៅមុខទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោតនៃឃុំ សង្កាត់ យ៉ាងតិច ៧ (ប្រាំពីរ) ថ្ងៃ មុនថ្ងៃចាប់ផ្តើមការចុះឈ្មោះបោះឆ្នោត
- បិទផ្សាយប្រតិទិននៃការចុះឈ្មោះបោះឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៥ ឆ្នាំ២០២៤ នៅមុខទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោតនៃឃុំ សង្កាត់ យ៉ាងតិច ៧ (ប្រាំពីរ) ថ្ងៃ មុនថ្ងៃចុះឈ្មោះបោះឆ្នោត

- បើកការិយាល័យចុះឈ្មោះបោះឆ្នោត ដើម្បីចុះឈ្មោះបោះឆ្នោត ចាប់ពីថ្ងៃទី១៨ ខែតុលា ដល់ថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០២៣ (មិនគិតបញ្ចូលថ្ងៃសៅរ៍ ថ្ងៃអាទិត្យ និងថ្ងៃបុណ្យផ្លូវការ) ។ ប្រធាន កបឃ.ស ត្រូវមានវត្តមាននៅការិយាល័យចុះឈ្មោះបោះឆ្នោត ក្នុងអំឡុងពេលនៃការចុះឈ្មោះបោះឆ្នោត ដើម្បីស្រង់ឈ្មោះ និងចុះឈ្មោះជូនសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែង និងបំពេញទម្រង់បញ្ជីឈ្មោះសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែង និងផ្តល់ព័ត៌មានឱ្យបានគ្រប់គ្រាន់ដល់សមាជិក កបឃ.ស ក្នុងតំណែងទាំងនោះ ។ ប្រធាន កបឃ.ស ត្រូវ ៖
  - ➢ ស្រង់ឈ្មោះ និងទិន្នន័យសមាជិក កបឃ.ស ក្នុងតំណែង និងផ្ទៀងផ្ទាត់លក្ខខណ្ឌសម្រាប់ការចុះឈ្មោះបោះឆ្នោត ។ ក្នុងករណីពិនិត្យឃើញថាត្រឹមត្រូវពិតប្រាកដហើយ ត្រូវចុះឈ្មោះគាត់ដោយដៃចូលទៅក្នុងបញ្ជីឈ្មោះសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែង តាមគំរូដែលផ្តល់ជូនស្រាប់ដោយ គ.ជ.ប ឬអាចរៀបចំក្នុងប្រព័ន្ធកុំព្យូទ័រ តាមគំរូដែលផ្តល់ជូនស្រាប់ដោយ គ.ជ.ប
  - ➢ ធានាថាឈ្មោះ និងទិន្នន័យសមាជិក កបឃ.ស ក្នុងតំណែងដែលបានចុះក្នុងបញ្ជីឈ្មោះសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែង ដូចគ្នាជាមួយនឹងឈ្មោះ និងទិន្នន័យរបស់សមាជិក កបឃ.ស ក្នុងតំណែងនៅលើ អ.ខ ឬលិខិតសម្គាល់ខ្លួនជាសមាជិក កបឃ.ស ក្នុងតំណែងដែលចេញដោយស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ
- បន្ទាប់ពីចុះឈ្មោះ និងទិន្នន័យសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែង និងពិនិត្យ ផ្ទៀងផ្ទាត់ឈ្មោះ និងទិន្នន័យ បានត្រឹមត្រូវហើយ ត្រូវថតចម្លងបញ្ជីឈ្មោះសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែង បង្គ្រប់ចំនួន ៥ (ប្រាំ) ច្បាប់ រួចប្រធាន កបឃ.ស ត្រូវចុះហត្ថលេខា ចុះកាលបរិច្ឆេទ និងបោះត្រារដ្ឋបាលឃុំ សង្កាត់ លើបញ្ជីឈ្មោះសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែង និងរៀបចំបញ្ជីឈ្មោះទាំងនោះដើម្បីស្នើសុំបញ្ជាក់ការឯកភាព តាមលំដាប់ឋានានុក្រមពីអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ដែលក្នុងនោះត្រូវ ៖
  - ➢ រក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ នៅសាលាឃុំ សង្កាត់
  - ➢ ផ្ញើ ៤ (បួន) ច្បាប់ ដើម្បីស្នើសុំបញ្ជាក់ការឯកភាពតាមលំដាប់ឋានានុក្រមពីអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត
- ធ្វើរបាយការណ៍សរុបលទ្ធផលនៃការចុះឈ្មោះបោះឆ្នោតនៅការិយាល័យចុះឈ្មោះបោះឆ្នោតនៃអង្គបោះឆ្នោតសមាជិក កបឃ.ស តាមគំរូទម្រង់ដែល គ.ជ.ប បានផ្តល់ជូន ចំនួន ៣ (បី) ច្បាប់ រួចចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រារដ្ឋបាលឃុំ សង្កាត់ ហើយចាត់ចែងប្រើប្រាស់ដូចខាងក្រោម ៖

- រក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ នៅសាលាឃុំ សង្កាត់
- ផ្ញើ ១ (មួយ) ច្បាប់ ជូន លធ.ខប ពាក់ព័ន្ធ
- ផ្ញើ ១ (មួយ) ច្បាប់ ជូន គ.ជ.ប តាមរយៈអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត

- ក្រោយពីបញ្ជូនបញ្ជីឈ្មោះសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែង មក គ.ជ.ប ក្នុងករណីមានអ្នកបោះឆ្នោតណាម្នាក់ ឬច្រើននាក់ ដែលបានចុះឈ្មោះក្នុងបញ្ជីបោះឆ្នោតដែលជាសមាជិក កបឃ.ស រួចហើយ ប៉ុន្តែបែរជាលែងស្ថិតក្នុងមុខតំណែងជាសមាជិក កបឃ.ស តទៅទៀត និងដែលមានសមាជិក កបឃ.ស ក្នុងតំណែងថ្មីចូលមកជំនួសជាផ្លូវការ កបឃ.ស ត្រូវលើកសំណើសុំកែតម្រូវបញ្ជីបោះឆ្នោតដោយមានការបញ្ជាក់ឯកភាពតាមលំដាប់ឋានានុក្រមមក គ.ជ.ប យ៉ាងយូរត្រឹមថ្ងៃទី៣ ខែមករា ឆ្នាំ២០២៤ ។

## IV- **អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ**

នៅពេលទទួលបានបញ្ជីឈ្មោះសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែង និងរបាយការណ៍សរុបលទ្ធផលនៃការចុះឈ្មោះបោះឆ្នោតពីឃុំ សង្កាត់នានា ដែលស្ថិតក្នុងក្រុង ស្រុក ខណ្ឌ អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវពិនិត្យ និងផ្ទៀងផ្ទាត់បញ្ជីឈ្មោះសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែងនៃឃុំ សង្កាត់នីមួយៗ និងត្រូវចាត់ចែងជាបន្ទាន់ ៖

- បញ្ជាក់ឯកភាពលើបញ្ជីឈ្មោះសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែងនៃឃុំ សង្កាត់នីមួយៗ ក្នុងករណីត្រឹមត្រូវពិតប្រាកដ
- សុំឱ្យប្រធាន កបឃ.ស បកស្រាយបំភ្លឺ ឬ/និងកែតម្រូវ ក្នុងករណីមានលក្ខណៈមិនត្រឹមត្រូវ ។ បន្ទាប់ពីបានកែតម្រូវរួចត្រូវបញ្ជាក់ឯកភាពលើបញ្ជីឈ្មោះសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែងនៃឃុំ សង្កាត់នោះ
- រៀបចំបញ្ជីឈ្មោះសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែងដែលបានបញ្ជាក់ឯកភាពរួចហើយចំនួន ៣ (បី) ច្បាប់ និងរបាយការណ៍ទាំង ២ (ពីរ) ច្បាប់ ដោយដាក់តាមឃុំ សង្កាត់នីមួយៗ ដើម្បីបញ្ជូនទៅសាលារាជធានី ខេត្ត និងត្រូវធ្វើដីកាអមបញ្ជូនបញ្ជីឈ្មោះ និងរបាយការណ៍នៃឃុំ សង្កាត់ទាំងអស់ដែលស្ថិតក្នុងក្រុង ស្រុក ខណ្ឌ ជូនអភិបាលនៃគណៈអភិបាលរាជធានី ខេត្តផង
- រក្សាទុកបញ្ជីឈ្មោះសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែង ដែលបានបញ្ជាក់ឯកភាពរួចហើយ ចំនួន ១ (មួយ) ច្បាប់ ជាឯកសារនៅសាលាក្រុង ស្រុក ខណ្ឌ ។

## V- **អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត**

នៅពេលទទួលបានបញ្ជីឈ្មោះសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែង និងរបាយការណ៍សរុបលទ្ធផលនៃការចុះឈ្មោះបោះឆ្នោតពីឃុំ សង្កាត់នានាដែលស្ថិតក្នុងរាជធានី ខេត្ត អភិបាល

នៃគណៈអភិបាលរាជធានី ខេត្តត្រូវពិនិត្យ និងផ្ទៀងផ្ទាត់បញ្ជីឈ្មោះសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែងនៃឃុំ សង្កាត់នីមួយៗ ដែលអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌបានបញ្ជាក់ឯកភាពរួចហើយ និងត្រូវចាត់ចែងជាបន្ទាន់ ៖

- បញ្ជាក់ឯកភាពលើបញ្ជីឈ្មោះសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែងនៃឃុំ សង្កាត់នីមួយៗ ក្នុងករណីត្រឹមត្រូវពិតប្រាកដ
- សុំឱ្យប្រធាន កបឃ.ស និងអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌបកស្រាយបំភ្លឺ ឬ/និងកែតម្រូវ ក្នុងករណីមានលក្ខណៈមិនត្រឹមត្រូវ ។ បន្ទាប់ពីបានកែតម្រូវរួច ត្រូវបញ្ជាក់ឯកភាពលើបញ្ជីឈ្មោះសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែងនៃឃុំ សង្កាត់នោះ
- រៀបចំបញ្ជីឈ្មោះសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែងដែលបានបញ្ជាក់ឯកភាពរួចហើយចំនួន ២ (ពីរ) ច្បាប់ និងរបាយការណ៍ទាំង ២ (ពីរ) ច្បាប់ ដោយដាក់តាមឃុំ សង្កាត់នីមួយៗ ដើម្បីបញ្ជូនទៅ គ.ជ.ប តាមរយៈ លធ.ខប
- រក្សាទុកបញ្ជីឈ្មោះសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែង ដែលបានបញ្ជាក់ឯកភាពរួចហើយ ចំនួន ១ (មួយ) ច្បាប់ ជាឯកសារនៅសាលារាជធានី ខេត្ត ។

ទទួលបានសេចក្តីណែនាំនេះ អគ្គលេខាធិការរដ្ឋសភា ប្រធាន លធ.ខប អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ និងប្រធាន កបឃ.ស ទាំងអស់ ត្រូវយកចិត្តទុកដាក់អនុវត្តឱ្យមានប្រសិទ្ធភាព ។

ថ្ងៃអង្គារ ៤រោច ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣ ខែតុលា ឆ្នាំ២០២៣

**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

**ប្រាជ្ញ ចន្ទ**

**កន្លែងទទួល ៖**

- ក្រុមប្រឹក្សាធម្មនុញ្ញ
- ព្រឹទ្ធសភា
- រដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ

"ដើម្បីជូនជ្រាប"

- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**
**លេខ:** ✓ **គ.ជ.ប**

ថ្ងៃអង្គារ ៤រោច ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ៣ ខែតុលា ឆ្នាំ២០២៣

## ប្រតិទិននៃការចុះឈ្មោះបោះឆ្នោត
## សម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៥ ឆ្នាំ២០២៤

| ល.រ | ភារកិច្ចដែលត្រូវបំពេញ | កាលបរិច្ឆេទ |
|---|---|---|
| ១ | ការរៀបចំទម្រង់បែបបទ និងឯកសារ | ថ្ងៃទី១០ ខែកញ្ញា ដល់ថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០២៣ |
| ២ | ផ្សព្វផ្សាយសេចក្ដីសម្រេចស្ដីពីការផ្ទេរសមត្ថកិច្ច និងការធ្វើប្រតិភូកម្មអំណាច | ថ្ងៃទី១ ខែតុលា ឆ្នាំ២០២៣ |
| ៣ | លធ.ខប ទំនាក់ទំនងជាមួយអាជ្ញាធរដែនដី គណបក្សនយោបាយ សមាគម អង្គការមិនមែនរដ្ឋាភិបាលដើម្បីផ្សព្វផ្សាយពីគោលបំណង ខ្លឹមសារ និងប្រតិទិននៃការចុះឈ្មោះបោះឆ្នោត | ថ្ងៃទី៤ ខែតុលា ឆ្នាំ២០២៣ |
| ៤ | លធ.ខប ផ្សព្វផ្សាយពីគោលបំណង ខ្លឹមសារ និងប្រតិទិននៃការស្រង់ឈ្មោះតំណាងរាស្ត្រក្នុងតំណែង និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ក្នុងមុខតំណែង ដល់អគ្គលេខាធិការដ្ឋានរដ្ឋសភា និងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ពាក់ព័ន្ធ | ថ្ងៃទី៩ ខែតុលា ឆ្នាំ២០២៣ |
| ៥ | អគ្គលេខាធិការដ្ឋានរដ្ឋសភា និងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ពាក់ព័ន្ធ បិទផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងប្រតិទិននៃការចុះឈ្មោះបោះឆ្នោត សម្រាប់ការបោះឆ្នោតជ្រើស-តាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៥ ឆ្នាំ២០២៤ | ថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៣ |
| ៦ | ការចុះឈ្មោះបោះឆ្នោតនៅអគ្គលេខាធិការដ្ឋានរដ្ឋសភា និងតាមសាលាឃុំ សង្កាត់ | ថ្ងៃទី១៨ ខែតុលា ដល់ថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០២៣ |
| ៧ | ការបញ្ជាក់តាមឋានានុក្រមនៅរដ្ឋសភា និងនៅក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត | ថ្ងៃទី៧ ដល់ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២៣ |
| ៨ | ការបញ្ជូនបញ្ជីឈ្មោះ និងរបាយការណ៍មក គ.ជ.ប | ថ្ងៃទី១៥ ដល់ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២៣ |
| ៩ | ការបញ្ចូលទិន្នន័យ ការពិនិត្យផ្ទៀងផ្ទាត់ ការបោះពុម្ព និងការវេចខ្ចប់នៅ គ.ជ.ប | ថ្ងៃទី២២ ខែវិច្ឆិកា ដល់ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២៣ |
| ១០ | ការសម្រេចលើបញ្ជីបោះឆ្នោតដំបូងដោយ គ.ជ.ប | ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២៣ ដល់ថ្ងៃទី៣ ខែមករា ឆ្នាំ២០២៤ |
| ១១ | ការបញ្ជូនបញ្ជីបោះឆ្នោតដំបូងទៅ លគធ.ខប | ថ្ងៃទី៣ ដល់ថ្ងៃទី៤ ខែមករា ឆ្នាំ២០២៤ |
| ១២ | ការបិទផ្សាយបញ្ជីបោះឆ្នោតដំបូងនៅតាមសាលាឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ និងនៅ លគធ.ខប | ថ្ងៃទី៥ ខែមករា ឆ្នាំ២០២៤ |
| ១៣ | ការប្ដឹងតវ៉ា ឬ/និងការប្ដឹងជំទាស់ និងការដោះស្រាយពាក្យបណ្ដឹងលើបញ្ជីបោះឆ្នោតដំបូង | ថ្ងៃទី៦ ខែមករា ដល់ថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២៤ |
| ១៤ | ការផ្ដល់សុពលភាពលើបញ្ជីបោះឆ្នោតផ្លូវការដោយ គ.ជ.ប | ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០២៤ |
| ១៥ | ការបិទផ្សាយបញ្ជីបោះឆ្នោតផ្លូវការដោយ គ.ក.ប នៅការិយាល័យបោះឆ្នោត | ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២៤ |
| ១៦ | ការរៀបចំបែបបទផ្លាស់ប្ដូរសមាជិកអង្គបោះឆ្នោតជំនួសអង្គបោះឆ្នោតដែលទទួលមរណភាព | ថ្ងៃទី៩ ដល់ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២៤ |